ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រដ្ឋបាលខេត្តប៉ៃលិន

# របាយការណ៍
# ស្តីពី
# វឌ្ឍនភាពរយៈពេល៥ឆ្នាំ (២០១៨-២០២៣)
# របស់រដ្ឋបាលខេត្តប៉ៃលិន

ថ្ងៃព្រហស្បតិ៍ ៤កើត ខែផល្គុន ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦
ប៉ៃលិន ថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០២៣

**ចំណងជើង** **ទំព័រ**


**មាតិកា**.......................................................................................................................i

**វឌ្ឍនភាពរយៈពេល៥ឆ្នាំ (២០១៨-២០២៣)**........................................................................... ១

**១-ស្ថានភាពទូទៅរបស់ខេត្តប៉ៃលិន**............................................................................... ១

**២-ការគ្រប់គ្រងរដ្ឋបាល** ............................................................................................. ១

**២.១. ការងាររដ្ឋបាល** ............................................................................................. ១

-ការអនុវត្តគម្រោងអភិវឌ្ឍន៍របស់រដ្ឋបាលខេត្ត ............................................................. ១

-ការផ្តល់សេវារដ្ឋបាលតាមយន្តការច្រកចេញចូលតែមួយ ......................................................២

**២.២. ការគ្រប់គ្រងរដ្ឋបាលដែនដី**............................................................................. ៤

**២.៣. ការងារគណៈបញ្ជាការឯកភាពរដ្ឋបាល**................................................................. ៤

**២.៤. ការគ្រប់គ្រងប្រើប្រាស់ដីធ្លី** .............................................................................. ៥

**៣. ផ្នែកសេដ្ឋកិច្ច** ............................................................................................................ ៥

វិស័យកសិកម្ម..................................................................................................... ៥

វិស័យពាណិជ្ជកម្ម ................................................................................................. ៦

វិស័យធនធានទឹក.....................................................................................................៧

វិស័យសាធារណការ និងអភិវឌ្ឍន៍ជនបទ.........................................................................៧

វិស័យទេសចរណ៍ ................................................................................................... ៨

**៤. ផ្នែកសង្គម**.................................................................................................................. ៩

វិស័យគាំពារសង្គម.................................................................................................. ៩

វិស័យសុខាភិបាល................................................................................................. ១០

វិស័យអប់រំ យុវជន និងកីឡា..................................................................................... ១១

**៥. រដ្ឋបាលសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ**.....................................................................១៣

សន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ................................................................................១៣

កិច្ចសហប្រតិបត្តិការស្រាវជ្រាវបង្ក្រាបបទល្មើស ..............................................................១៣

ការបង្ក្រាបគ្រឿងញៀន...........................................................................................១៣

ការបង្ក្រាបបទល្មើសជួញដូរមនុស្ស ...........................................................................១៣

ការបង្ក្រាបក្មេងទំនើង.............................................................................................១៣

ការបង្ក្រាបបទល្មើសល្បែងស៊ីសង...............................................................................១៣

**៦. លទ្ធផលបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ឆ្នាំ២០២២**........................................១៣

**៧. ទិសដៅការងារអនុវត្តបន្ត** ............................................................................................ ១៤

# របាយការណ៍
# ស្ដីពី
# វឌ្ឍនភាពរយៈពេល៥ឆ្នាំ (២០១៨-២០២៣) របស់រដ្ឋបាលខេត្តប៉ៃលិន

**១-ស្ថានភាពទូទៅរបស់ខេត្ត**

ខេត្តប៉ៃលិន ជាខេត្តមួយក្នុងចំណោយរាជធានី ខេត្តទាំង២៥ ស្ថិតនៅភាគពាយព្យ នៃព្រះរាជាណាចក្រកម្ពុជា ដែលមានចំងាយ ៣៧៥ គីឡូម៉ែត្រ តាមបណ្ដោយផ្លូវជាតិលេខ៥ និងលេខ៥៧ ពីរាជធានីភ្នំពេញមកខេត្តប៉ៃលិន។ មានព្រំប្រទល់ខាងកើតទល់នឹងស្រុករតនៈមណ្ឌល ខាងជើងទល់នឹងស្រុកកំរៀង ខាងត្បូងទល់នឹងស្រុកសំឡូត ខេត្តបាត់ដំបង និងខាងលិចទល់នឹងខេត្តចន្ទបុរី នៃព្រះរាជាណាចក្រថៃ មានព្រំប្រទល់ជាប់ព្រំដែនប្រវែង ៤៣ គីឡូម៉ែត្រ លាតសន្ធឹងចន្លោះពីស្រុកសំឡូត ដល់ស្រុកកំរៀង ខេត្តបាត់ដំបង។ ខេត្តប៉ៃលិន មានផ្ទៃដីសរុប ១.១៩៤,៦១ គីឡូម៉ែត្រក្រឡា ចែកចេញជា០១ក្រុង និង ០១ស្រុក មានឃុំចំនួន ០៤ សង្កាត់ចំនួន ០៤ និងមានភូមិចំនួន ៩៣ ភូមិ មានប្រជាពលរដ្ឋរស់នៅសរុបចំនួន ១៨.៥៨២ គ្រួសារ ស្មើនឹងមនុស្សរាយសរុបចំនួន ៧៨.៩៧៥ នាក់ ស្រី ៣៩.៤១៦ នាក់ អាយុ១៨ ឆ្នាំឡើងចំនួន ៥៤.៨៧៦ នាក់។ គិតជាដង់ស៊ីតេជាមធ្យមចំនួន ៧០ នាក់ ក្នុង១គីឡូម៉ែត្រក្រឡា។ ប្រជាពលរដ្ឋទូទៅមានកម្រិតGDP ១.៤៦៧,៨ ដុល្លារក្នុង១ឆ្នាំ។ ខេត្តប៉ៃលិន មានច្រកព្រំដែនអន្តរជាតិចំនួន១ គឺច្រកទ្វារព្រំដែនអន្តរជាតិព្រំ។

**២-ការគ្រប់គ្រងរដ្ឋបាល**

**២.១. ការងាររដ្ឋបាល**

ដោយយោងតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ និងផែនការអភិវឌ្ឍន៍ខេត្តរយៈពេល៥ឆ្នាំ និងកម្មវិធីវិនិយោគ៣ឆ្នាំរំកិល ដែលបានអនុម័តដោយក្រុមប្រឹក្សាខេត្ត។

❖ **ការអនុវត្តគម្រោងអភិវឌ្ឍន៍របស់រដ្ឋបាលខេត្ត ៖** ក្នុងរយៈពេល៥ឆ្នាំ (២០១៨-២០២២) រដ្ឋបាលខេត្ត មានគម្រោងអភិវឌ្ឍន៍សរុបចំនួន ២៨១ គម្រោង អនុវត្តបាន ១៥៩ គម្រោង និងមិនទាន់បានអនុវត្ត ៥៩ គម្រោង ក្នុងនោះមាន ផ្នែកសេដ្ឋកិច្ចមាន ១៣៧ គម្រោង អនុវត្តបាន ៨៦ គម្រោង មិនទាន់អនុវត្ត ៥១ គម្រោង ផ្នែកសង្គមកិច្ចមានចំនួន ៣២ គម្រោង មិនទាន់អនុវត្ត ១ គម្រោង ផ្នែធនធានធម្មជាតិ បរិស្ថាន និងការបន្សាំនឹងការប្រែប្រួលអាកាសធាតុមានចំនួន ១១ គម្រោង អនុវត្តបាន ១០ គម្រោង មិនទាន់អនុវត្ត ១ គម្រោង និងផ្នែករដ្ឋបាល និងសន្តិសុខសណ្ដាប់ធ្នាប់សាធារណៈមាន ៣៧ គម្រោង អនុវត្តបាន ៣១ គម្រោង និងមិនទាន់ អនុវត្ត ៦ គម្រោង។

**ការអនុវត្តគម្រោងអភិវឌ្ឍន៍របស់រដ្ឋបាលខេត្ត**

| ផ្នែកទាំង៤ | ឆ្នាំ២០១៨ | | ឆ្នាំ២០១៩ | | ឆ្នាំ២០២០ | | ឆ្នាំ២០២១ | | ឆ្នាំ២០២២ | | សរុប | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | អនុវត្តរួច | មិនទាន់អនុវត្ត | អនុវត្តរួច | មិនទាន់អនុវត្ត | អនុវត្តរួច | មិនទាន់អនុវត្ត | អនុវត្តរួច | មិនទាន់អនុវត្ត | អនុវត្តរួច | មិនទាន់អនុវត្ត | អនុវត្តរួច | មិនទាន់ |
| ១.ផ្នែកសេដ្ឋកិច្ច | 23 | - | 26 | 4 | 20 | 11 | 4 | 27 | 13 | 9 | 86 | 51 |
| ២.ផ្នែកសង្គមកិច្ច | 6 | - | 6 | - | 7 | 1 | 7 | - | 6 | - | 32 | 1 |
| ៣.ផ្នែកធនធានធម្មជាតិបរិស្ថាន និងការបន្សាំនឹងការប្រែប្រួលអាកាសធាតុ | 2 | 1 | 3 | - | 3 | - | 1 | - | 1 | - | 10 | 1 |
| ៤.ផ្នែករដ្ឋបាល និងសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ | 3 | - | 3 | - | 10 | - | 11 | - | 4 | 6 | 31 | 6 |
| **សរុប** | **34** | **1** | **38** | **4** | **40** | **12** | **23** | **27** | **24** | **15** | **159** | **59** |

❖ **ការផ្តល់សេវារដ្ឋបាលតាមយន្តការច្រកចេញចូលតែមួយ៖** យោងតាមអនុក្រឹត្យលេខ១៨ អនក្រ.បក ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០១៧ របស់រាជរដ្ឋាភិបាលកម្ពុជា ស្តីពីការបង្កើតយន្តការច្រកចេញចូលតែមួយសម្រាប់ការផ្តល់សេវារដ្ឋបាលនៅរដ្ឋបាលថ្នាក់ក្រោមជាតិ។ ជាមួយគ្នានេះ រដ្ឋបាលខេត្តប៉ៃលិន បានចាប់ផ្តើមដំណើរការអង្គភាពច្រកចេញចូលតែមួយនៅឆ្នាំ២០១៨ រហូតមកដល់ពេលនេះគឺមានរយៈពេល ៥ឆ្នាំមកហើយ។ ការផ្តល់សេវាតាមយន្តការច្រកចេញចូលតែមួយនេះ បានបង្ករលក្ខណៈងាយស្រួល និងឆ្លើយតបទាន់ពេលវេលាទៅនឹងតម្រូវការរបស់ប្រជាពលរដ្ឋនៅនឹងមូលដ្ឋាន។ ជាលទ្ធផលក្នុងរយៈពេល៥ឆ្នាំនេះ អង្គភាពច្រកចេញចូលតែមួយខេត្ត បានផ្តល់សេវាលើវិស័យចំនួន **១៥** ស្មើនឹង **៣៣.៧៩៩** សេវា ទទួលបានចំណូលពីសេវាចំនួន **២.៤៨៦.០៤៤.៦៥០ រៀល** (ពីរប៊ីលាន បួនរយប៉ែតសិបប្រាំមួយលាន សែសិបបួនពាន់ ប្រាំមួយរយហាសិបរៀល) ក្នុងនោះមាន ការធ្វើនីត្យានុកូលកម្មលើឯកសារនានា ៤៨៧ សេវា វិស័យរដ្ឋបាល ១៧.៤២៦ សេវា វិស័យសុខាភិបាល ២៦ សេវា វិស័យទេសចរណ៍ ១០៩ សេវា វិស័យសាធារណការ និងដឹកជញ្ជូន ៩.៤០៣ សេវា វិស័យវប្បធម៌ និងវិចិត្រសិល្បៈ ០៦ សេវា វិស័យ ព័ត៌មាន ៩៣ សេវា វិស័យបរិស្ថាន ៧៦ សេវា វិស័យឧស្សាហកម្ម និងសិប្បកម្ម ៩៧ សេវា វិស័យរ៉ែ និងថាមពល ៤២ សេវា វិស័យពាណិជ្ជកម្ម ៧១ សេវា វិស័យសំណង់ ៤៩ សេវា វិស័យសុរិយោដី ៤.៥៩៦ សេវា វិស័យកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ៨៧១ សេវា និងវិស័យការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ៤៤៧ សេវា។

## ការផ្តល់សេវាសាធារណៈតាមរយៈយន្តការច្រកចេញចូលតែមួយ រយៈពេល៥ឆ្នាំ (២០១៨-២០២២) ខេត្តប៉ៃលិន

| ល.រ | ឈ្មោះសេវាតាមវិស័យនីមួយៗ | 2018 | | 2019 | | 2020 | | 2021 | | 2022 | | សរុបរួម | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | ចំនួន | ទឹកប្រាក់ | ចំនួន | ទឹកប្រាក់ | ចំនួន | ទឹកប្រាក់ | ចំនួន | ទឹកប្រាក់ | ចំនួន | ទឹកប្រាក់ | ចំនួន | ទឹកប្រាក់ |
| ១ | នីត្យានុកូលកម្ម | 177 | 889,000 | 20 | 141,000 | 200 | 1,688,000 | 63 | 527,000 | 27 | 277,000 | 487 | 3,522,000 |
| ២ | ការងាររដ្ឋបាល | 3,627 | 72,540,000 | 809 | 16,140,000 | 5,716 | 121,300,000 | 13 | 7,280,000 | 7,261 | 154,650,000 | 17,426 | 371,910,000 |
| ៣ | សុខាភិបាល | - | - | 1 | 900,000 | 11 | 5,160,000 | 2 | 840,000 | 12 | 5,160,000 | 26 | 12,060,000 |
| ៤ | ទេសចរណ៍ | 5 | 4,400,000 | 1 | 600,000 | 26 | 11,465,000 | 40 | 10,560,000 | 37 | 18,830,000 | 109 | 45,855,000 |
| ៥ | សាធារណការ និងដឹកជញ្ជូន | - | - | - | 260,000 | 9 | 3,000,000 | 2,364 | 223,294,000 | 7,030 | 594,806,500 | 9,403 | 821,360,500 |
| ៦ | វប្បធម៌ និងវិចិត្រសិល្បៈ | - | - | - | - | 2 | 400,000 | 2 | 400,000 | 2 | 400,000 | 6 | 1,200,000 |
| ៧ | ព័ត៌មាន | - | - | - | - | 7 | 3,840,000 | 53 | 37,642,000 | 33 | 31,800,000 | 93 | 73,282,000 |
| ៨ | បរិស្ថាន | - | - | - | - | 9 | 4,500,000 | 25 | 2,600,000 | 42 | 4,300,000 | 76 | 11,400,000 |
| ៩ | ឧស្សាហកម្ម និងសិប្បកម្ម | - | - | - | - | 32 | 3,720,000 | 29 | 3,660,000 | 36 | 4,150,000 | 97 | 11,530,000 |
| ១០ | រ៉ែ និងថាមពល | 9 | 750,000 | - | - | 33 | 2,750,000 | - | - | - | - | 42 | 3,500,000 |
| ១១ | ពាណិជ្ជកម្ម | 42 | 1,680,000 | 4 | 160,000 | 25 | 1,000,000 | - | - | - | - | 71 | 2,840,000 |
| ១២ | សំណង់ | 4 | 1,446,500 | 2 | 10,428,000 | 1 | - | 26 | 39,310,120 | 16 | 10,404,500 | 49 | 61,589,120 |
| ១៣ | សុរិយោដី | - | - | 55 | 13,700,000 | 486 | 177,896,012 | 632 | 230,326,600 | 3,423 | 529,232,918 | 4,596 | 951,155,530 |
| ១៤ | កសិកម្មរុក្ខាប្រមាញ់ និងនេសាទ | - | 3,330,000 | - | - | 579 | 27,851,000 | 151 | 34,460,500 | 141 | 35,599,000 | 871 | 101,240,500 |
| ១៥ | ការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | 158 | - | 78 | 2,400,000 | 140 | 8,920,000 | 57 | 1,780,000 | 14 | 500,000 | 447 | 13,600,000 |
| | សរុប | 4,022 | 85,035,500 | 970 | 44,729,000 | 7,276 | 373,490,012 | 3,457 | 592,680,220 | 18,074 | 1,390,109,918 | 33,799 | 2,486,044,650 |

### ២.២. ការគ្រប់គ្រងរដ្ឋបាលដែនដី

រដ្ឋបាលខេត្ត ក្រុង ស្រុក និងឃុំ សង្កាត់បានអនុវត្តតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល រក្សាបានសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ សោភ័ណភាព និងការអភិវឌ្ឍតាមរយៈយន្តការក្រុមប្រឹក្សា គណៈអភិបាល គណៈបញ្ជាការឯកភាពរដ្ឋបាលខេត្ត ក្រុង ស្រុក និងគណៈកម្មាធិការនានារបស់ក្រុមប្រឹក្សានៃរដ្ឋបាលនីមួយៗ។ ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុង ស្រុក ក្រុមប្រឹក្សាឃុំ សង្កាត់ បានអនុវត្តយ៉ាងសកម្មតាមច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងដោយមានការណែនាំពីរាជរដ្ឋាភិបាល ក៏ដូចជាក្រសួងមហាផ្ទៃ និងគណៈកម្មាធិការជាតិសម្រាប់អភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ តាមរយៈអនុក្រឹត្យ ប្រកាស លិខិតបទដ្ឋានគតិយុត្ត ដើម្បីឱ្យរដ្ឋបាលខេត្ត ក្រុង ស្រុក និងឃុំ សង្កាត់ បានអនុវត្តប្រកបដោយប្រសិទ្ធភាព។ ក្រុមប្រឹក្សាខេត្តប៉ៃលិន អាណត្តិទី៣ មានចំនួន ១៥ នាក់ (ស្រី ៣នាក់) និងក្រុមប្រឹក្សាក្រុង ស្រុក មានចំនួន ៣០ នាក់។ ក្រុមប្រឹក្សាខេត្ត បានខិតខំអនុវត្ត តួនាទី ភារកិច្ច តាមរយៈយន្តការគណៈកម្មាធិការនានារបស់ក្រុមប្រឹក្សា បានដាក់ចេញនូវដីកា សេចក្តីសម្រេច ផែនការអភិវឌ្ឍន៍រយៈពេលប្រាំឆ្នាំ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលរបស់ខ្លួន ដើម្បីសម្រេចនូវគោលបំណងក្នុងការធ្វើឱ្យមានចីរភាពដល់ការអភិវឌ្ឍតាមបែបប្រជាធិតេយ្យនៅថ្នាក់ក្រោមជាតិ ព្រមទាំងបំពេញមុខងារភារកិច្ចដែលបានប្រគល់ និងបានធ្វើប្រតិភូកម្មស្របតាមច្បាប់កំណត់ក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។ បានពង្រឹងការផ្តល់សេវាសាធារណៈស្របតាមគោលការណ៍ណែនាំរបស់ក្រសួងមហាផ្ទៃ និងរាជរដ្ឋាភិបាល ពិសេសពង្រឹងការផ្តល់សេវាតាមយន្តការច្រកចេញចូលតែមួយ នៃរដ្ឋបាលខេត្ត ក្រុង ស្រុក និងឃុំ សង្កាត់។

រដ្ឋបាលខេត្ត ក្រុង ស្រុក និងរដ្ឋបាលឃុំ សង្កាត់បានអនុវត្តគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការ និងអនុវត្តតាមកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ដោយបានអនុវត្តបញ្ចប់នូវកម្មវិធីជាតិរយៈពេល១០ឆ្នាំដំណាក់កាលទី១ (ឆ្នាំ២០១០-២០២០) សម្រេចបាននូវសមិទ្ធផលធំៗជាច្រើនពាក់ព័ន្ធនឹងការរៀបចំដាក់ឱ្យដំណើរការ ស្ថាប័នរដ្ឋបាលថ្នាក់ក្រោមជាតិ គឺ ការប្រកាសដាក់ឱ្យដំណើរការរចនាសម្ព័ន្ធថ្មីរបស់រដ្ឋបាលក្រុង ស្រុក កាលពីចុងឆ្នាំ២០១៩កន្លងទៅ និងបានកំពុងអនុវត្តមុខងារដែលបានផ្ទេរពីថ្នាក់ជាតិចំនួន ៥៥ និងមុខងាររងចំនួន ១៦២ ។ បច្ចុប្បន្នរដ្ឋបាលខេត្ត ក្រុង ស្រុក និង ឃុំ សង្កាត់ បាននិងកំពុងបន្តជំរុញការអនុវត្តគោលនយោបាយកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការរបស់រាជរដ្ឋាភិបាលឱ្យកាន់តែស៊ីជម្រៅបន្ថែមទៀត តាមរយៈនៃការអនុវត្ត "កម្មវិធីជាតិសម្រាប់ការអភិវឌ្ឍនតាម បែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ដំណាក់កាលទី២ រយៈពេល១០ឆ្នាំ ពីឆ្នាំ២០២១-ឆ្នាំ២០៣០។

### ២.៣. ការងារគណៈបញ្ជាការឯកភាពរដ្ឋបាល

គណៈបញ្ជាការឯកភាពរដ្ឋបាលខេត្ត គណៈបញ្ជាការឯកភាពរដ្ឋបាលក្រុង ស្រុក បានយកចិត្តទុកដាក់លើការអនុវត្តច្បាប់ ថែរក្សាសន្តិសុខ សណ្តាប់ធ្នាប់ សោភណ៌ភាព និងការអភិវឌ្ឍដោយបានចុះអន្តរាគមន៍ ជួយសង្គ្រោះបានទាន់ពេលវេលា រួមសុខរួមទុក្ខជាមួយប្រជាពលរដ្ឋ ព្រមទាំងបានពង្រឹង និង

ថែរក្សាសន្តិសុខ នយោបាយ សន្តិសុខសង្គម សុវត្ថិភាពនៅមូលដ្ឋាន តាមរយៈការអនុវត្តគោលនយោបាយ "ភូមិ ឃុំ សង្កាត់មានសុវត្ថិភាព"។

អាជ្ញាធរមូលដ្ឋានមានការទទួលខុសត្រូវ លើការពង្រឹងសន្តិសុខនយោបាយ និងសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ មានភាពកាន់តែប្រសើរឡើង។ ជាលទ្ធផលចាប់តាំងពីឆ្នាំ ២០១៨-២០២២ ឃុំ សង្កាត់ ខេត្តប៉ៃលិនរក្សាបាននូវសុខសុវត្ថិភាពជូនប្រជាពលរដ្ឋរស់នៅដោយភាពសុខសាន្ត ជាក់ស្តែងដំណើរការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៥ ឆ្នាំ២០២២កន្លងទៅ ខេត្តប៉ៃលិន បានដំណើរការយ៉ាងល្អប្រសើរ ត្រឹមត្រូវ សេរី យុត្តិធម៌ ធានាបាននូវសុវត្ថិភាពគ្មានការគំរាមកំហែង គ្មានការបំភិតបំភ័យ គ្មានអំពើហិង្សា ធានាបាននូវសុខសន្តិភាព សុវត្ថិភាព ស្ថិរភាពសង្គម ហើយមានការទទួលស្គាល់ពីគណបក្សនយោបាយ និងសង្គមអន្តរជាតិ។ ទន្ទឹមនឹងនោះ រដ្ឋបាលខេត្ត រដ្ឋបាលក្រុង ស្រុក និងឃុំ សង្កាត់ បានពង្រឹងវិធានការនៃការកាត់បន្ថយគ្រោះថ្នាក់ចរាចរណ៍ ការពង្រឹងវិធានការការពារ ដីព្រៃដីរដ្ឋ ព្រៃសហគមន៍ ដីចំណីផ្លូវ ការរក្សាសន្តិសុខជូនថ្នាក់ដឹកនាំប្រជាពលរដ្ឋ ពិធីបុណ្យជាតិ និងអន្តរជាតិ។ បានពង្រឹងវិធានការបង្ក្រាបល្បែងស៊ីសង គ្រឿងញៀន ក្មេងទំនើង បង្ការអគ្គិភ័យ និងបង្ការបង្ក្រាបការជួញដូរមនុស្ស មានវិធានការបង្ការ ទប់ស្កាត់បាននូវការញុះញង់ ភូតកុហកបោកប្រាស់ ការបំផ្លើសការពិត របស់ពួកជនអគតិ និងបានគាំទ្រដល់មន្ទីរ អង្គភាពជំនាញជុំវិញខេត្តក្នុងការអនុវត្តច្បាប់ និងគោលការណ៍នានាក្នុងដែនសមត្ថកិច្ចរបស់ខ្លួនជាប្រចាំ។

### ២.៤. ការគ្រប់គ្រងប្រើប្រាស់ដីធ្លី

ការគ្រប់គ្រង និងប្រើប្រាស់ដីធ្លីនៅក្នុងខេត្តប៉ៃលិន រដ្ឋបាលខេត្តបានកាត់បន្ថយទំនាស់ដីធ្លី តាមរយៈផ្តល់ឱ្យប្រជាពលរដ្ឋយល់ដឹងពីច្បាប់ភូមិបាល និងយល់ដឹងពីសិទ្ធិកាន់កាប់ដីធ្លីត្រឹមត្រូវតាមច្បាប់ ដោយប្រើប្រាស់នូវផែនការគ្រប់គ្រង និងប្រើប្រាស់ដីធ្លី បានចេញប័ណ្ណកម្មសិទ្ធិជូនប្រជាពលរដ្ឋ តាមរយៈការចុះបញ្ជីដីធ្លីតាមបទបញ្ជាលេខ ០១បប ស្តីពីការអនុវត្តនយោបាយចាស់សកម្មភាពថ្មីលើវិស័យដីធ្លីរបស់រាជរដ្ឋាភិបាល ការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធ និងការចុះបញ្ជីដីធ្លីមានលក្ខណៈដាច់ដោយដុំ។ ខេត្តបានរៀបចំកម្មវិធីសម្បទានដីសង្គមកិច្ចជូនគ្រួសារស៊ីវិលក្រីក្រ និងកម្មវិធីសម្បទានដីសង្គមកិច្ចជូនកងកម្លាំងប្រដាប់អាវុធ និងគ្រួសារ។ តាមរយៈយន្តការគណៈកម្មការសុរិយោដី បានជួយធ្វើការដោះស្រាយវិវាទដីធ្លីជូនប្រជាពលរដ្ឋ ប្រកបដោយតម្លាភាព និងប្រសិទ្ធភាពដោយមានការឯកភាពទទួលស្គាល់សារទរពីគ្រប់មជ្ឈដ្ឋាន។

## ៣. ផ្នែកសេដ្ឋកិច្ច

❖ **វិស័យកសិកម្ម៖** គោលដៅសំខាន់វិស័យកសិកម្មរបស់ខេត្ត ដើម្បីធានាឱ្យបាននូវសន្តិសុខស្បៀង បង្កើនប្រាក់ចំណូល ធ្វើឱ្យប្រសើរឡើងនូវស្ថានភាពអាហារូបត្ថម្ភសម្រាប់ប្រជាជន តាមរយៈការបង្កើនផលិតភាពកសិកម្មឱ្យកសិករមានបច្ចេកទេសប្រើប្រាស់ពូជ ជី ការដាំដុះបង្កើនរដូវ ការធ្វើពិពិធកាវូបនីយកម្ម ការចិញ្ចឹមសត្វ និងការគាំទ្រសហគមន៍កសិកម្ម ក្នុងការដាំដុះផលិតផលកសិកម្ម ឆ្លើយតបតម្រូវការទីផ្សារ។ ផលិតផលកសិកម្មដំណាំស្រូវតែងសម្រេចបានលើសផែនការជារៀងរាល់ឆ្នាំ ការគិតគូរតុល្យភាពស្បៀងនៅក្នុងខេត្ត នៅសល់ស្រូវអង្ករមួយចំនួនសម្រាប់លក់នៅលើទីផ្សារ និងបានរួមចំណែក

លើកស្ទួយជីវភាពប្រជាពលរដ្ឋ។ ជាក់ស្តែងក្នុងរយៈពេល៥ឆ្នាំ (២០១៨-២០២២) ខេត្តបានប្រើប្រាស់ផ្ទៃដីដាំដុះដំណាំស្រូវចំនួន ៨.៩៣០ ហិកតា ផ្ទៃដីដំណាំសាកវប្បកម្មចំនួន ១២.២៥៧ ហិកតា និងផ្ទៃដីដាំដុះដំណាំឧស្សាហកម្មចំនួន ៥១.៧៥៩ ហិកតា។ រី ឯ បរិមាណផលដំណាំកសិកម្មទទួលបានដំណាំស្រូវចំនួន ១២៤.៣៦៨ តោន ដំណាំសាកវប្បកម្មចំនួន ៥៩៤.៣៧៦ តោន និងដំណាំឧស្សាហកម្ម ៤.០៤១.៨៤៥ តោន។ ពាក់ព័ន្ធនឹងវិស័យនេះ រដ្ឋបាលខេត្ត បានខិតខំជម្រុញនូវយន្តការអភិវឌ្ឍន៍ ដូចជាការអប់រំ បណ្តុះបណ្តាលបច្ចេកទេសក្នុងការប្រើប្រាស់ជី ថ្នាំកសិកម្ម និងជម្រុញនូវការប្រើប្រាស់ពូជប្រកបដោយគុណភាពដល់ប្រជាកសិករ ក្នុងគោលដៅបង្កើនទិន្នផល និងលើកកម្ពស់សេដ្ឋកិច្ចគ្រួសារកាត់បន្ថយភាពក្រីក្រ។

**តារាងផ្ទៃដីដាំដុះដំណាំកសិកម្មរយៈពេល៥ឆ្នាំ២០១៨-២០២២ (គិតជាហិកតា)**

| ឈ្មោះសូចនាករ | ផ្ទៃដីដាំដុះ(គិតជាហិកតា) | | | | |
|---|---|---|---|---|---|
| | ឆ្នាំ២០១៨ | ឆ្នាំ២០១៩ | ឆ្នាំ២០២០ | ឆ្នាំ២០២១ | ឆ្នាំ២០២២ |
| ១. ផលិតកម្មដំណាំស្រូវ | 8,800 | 8,930 | 6,879 | 7,770 | 8,000 |
| ២. ផលិតកម្មដំណាំសាកវប្បកម្ម | 3,258 | 12,257 | 11,065 | 9,996 | 10,111 |
| ៣. ផលិតកម្មដំណាំឧស្សាហកម្ម | 20,863 | 50,489 | 10,474 | 51,759 | 54,051 |

**បរិមាណផលដំណាំកសិកម្មរយៈពេល៥ឆ្នាំ២០១៨-២០២២**

| ឈ្មោះសូចនាករ | បរិមាណផល(តោន) | | | | |
|---|---|---|---|---|---|
| | ឆ្នាំ២០១៨ | ឆ្នាំ២០១៩ | ឆ្នាំ២០២០ | ឆ្នាំ២០២១ | ឆ្នាំ២០២២ |
| ១.ផលិតកម្មដំណាំស្រូវ | 26,400 | 26,790 | 20,637 | 24,786 | 25,755 |
| ២.ផលិតកម្មដំណាំសាកវប្បកម្ម | 26,064 | 102,186 | 134,316 | 152,864 | 178,946 |
| ៣.ផលិតកម្មដំណាំឧស្សាហកម្ម | 354,195 | 874,500 | 928,720 | 954,806 | 929,624 |

❖ **វិស័យពាណិជ្ជកម្ម៖** ដោយសារសក្តានុពលនៃទិន្នផលកសិកម្ម ខេត្តប៉ៃលិនមានសៃឡូចំនួន ៥៤ កន្លែង សម្រាប់ទិញកសិផលពីប្រជាពលរដ្ឋទូទាំងខេត្ត សម្រាប់ស្តុក និងនាំចេញទៅក្រៅប្រទេស។ ជាមួយគ្នានេះ ខេត្តប៉ៃលិន មានច្រកទ្វារព្រំដែនអន្តរជាតិព្រំ ដែលអាចសម្រួលដល់ការដោះដូរផលិតផលកសិកម្មរវាងប្រជាពលរដ្ឋនៃប្រទេសទាំងពីរ កម្ពុជា-ថៃ។ ជាក់ស្តែងក្នុងរយៈពេល៥ឆ្នាំ បរិមាណនៃការនាំចេញកសិផលទៅក្រៅប្រទេសមានចំនួនសរុប **២.១១៤.៩៩០** តោន ក្នុងនោះមាន ដំឡូងមីស្រស់ចំនួន **៣៩៧.៨៤៥** តោន ដំឡូងមីស្ងួតចំនួន **១.១១៥.៧៨៨** តោន ពោតក្រហមគ្រាប់ចំនួន **៣៤,៥០០** តោន ពោតស្ងួល **៤៨.៣៧០** តោន ស្វាយកែវល្មៀតចំនួន **៥២៨.៥៨៩** តោន មៀនប៉ៃលិន **៦.៩០៧** តោន ម្ទេស **៩៤៩** តោន និងល្ពៅ **៤២** តោន។ ក្នុងរយៈពេលថ្មីៗនេះ ពោតក្រហមមានតម្លៃ ៨៣៣ រៀល (ពោតស្ងួល) ពោតគ្រាប់តម្លៃ **១.៥០០** រៀល ដំឡូងមីស្រស់តម្លៃ ៣,១ បាត (លុយថៃ) ពោតស្ងួតតម្លៃ ៧,៥ បាត ស្វាយកែវមៀតចំរុះតម្លៃ ៥ បាត និងស្វាយកែវល្មៀតខ្ចប់តម្លៃ ១២ បាត។

**ការនាំចេញផលិតផលកសិកម្មរយៈពេល៥ឆ្នាំ (២០១៨-២០២២) ខេត្តប៉ៃលិន**

| **បរិយាយ** | **ការនាំចេញផលិតផលកសិកម្មរយៈពេល៥ឆ្នាំ (គិតជាតោន)** | | | | | **សរុបរួម** |
|---|---|---|---|---|---|---|
| | **២០១៨** | **២០១៩** | **២០២០** | **២០២១** | **២០២២** | |
| ដំឡូងមីស្រស់ | 109,880 | 43,930 | 23,265 | 39,360 | 163,410 | **379,845** |
| ដំឡូងមីស្ងួត | 87,132 | 104,355 | 405,361 | 242,370 | 276,570 | **1,115,788** |
| ពោតក្រហម (គ្រាប់) | | 14,100 | 20,400 | | | **34,500** |
| ពោតស្ងួល | 47,500 | 820 | | | | **48,370** |
| ស្វាយកែវរមៀត | 58,750 | 57,392 | 71,152 | 177,310 | 163,985 | **528,589** |
| មៀនប៉ៃលិន | 4,166 | 2,741 | | | | **6,907** |
| ម្ទេស | | 949 | | | | **949** |
| ល្ពៅ | | | 42 | | | **42** |
| **សរុប** | **307,478** | **224,287** | **520,220** | **459,040** | **603,965** | **2,114,990** |

❖ **វិស័យធនធានទឹក៖** រដ្ឋបាលខេត្ត បានយកចិត្តទុកដាក់ក្នុងការកសាងនូវប្រព័ន្ធធារាសាស្ត្រក្នុងន័យទ្រទ្រង់នូវការផ្គត់ផ្គង់ទឹកទូទាំងខេត្តទាំងមូល ជាពិសេសក្នុងវិស័យកសិកម្ម ទប់ស្កាត់ហានិភ័យដែលបណ្ដាលមកពីគ្រោះធម្មជាតិ ទឹកជំនន់ គ្រោះរាំងស្ងួត ឆ្លើយតបទៅនឹងតម្រូវការរបស់ប្រជាពលរដ្ឋផ្ទាល់។ ជាក់ស្ដែងក្នុងរយៈពេល៥ឆ្នាំ ខេត្តប៉ៃលិន បានជីកប្រឡាយថ្មីគ្រប់ប្រភេទចំនួន ១៥ខ្សែ ដែលមានប្រវែងសរុប ១៩.៥០០ ម៉ែត្រ។ សាងសង់សំណង់ធារាសាស្ត្រ និងសំណង់សិល្បការគ្រប់ប្រភេទចំនួន ១៩ កន្លែង។ សាងសង់ប្រព័ន្ធធារាសាស្ត្រកូនដំរីចំនួន ០១ កន្លែងថ្មីបន្ថែមទៀត ក្នុងនោះមាន៖ សំណង់បង្ហៀរទឹក ០១ កន្លែង ប្រវែង ៣០ ម៉ែត្រ ផ្លូវចូលសំណង់ក្រាលគ្រួសក្រហមប្រវែង ៣៥០ ម៉ែត្រ កូនប្រឡាយបេតុង ០១ ខ្សែ ប្រវែង ៤៨៦ ម៉ែត្រ លូប្រអប់ចំនួន ០២ កន្លែង និងស្ថានីយ៍បូមទឹក ០១ កន្លែង។ ជីកស្រះតាមពោះស្ទឹង និងអូរ យកទឹកប្រើប្រាស់បណ្ដោះអាសន្នបានចំនួន ០៥ កន្លែង និងស្ពានប្រឡាយជើងក្អែប ចំនួន ១៤ ខ្សែ ប្រវែង ៨.៨៧០ ម៉ែត្រ។

❖ **វិស័យសាធារណការ និងអភិវឌ្ឍន៍ជនបទ៖** ដោយមានកិច្ចសហការពីមន្ទីរសាធារណការ និងមន្ទីរអភិវឌ្ឍន៍ជនបទ រដ្ឋបាលខេត្ត បានស្ថាបនាផ្លូវបេតុងអាមេប្រវែង ៦.៣២១ ម៉ែត្រ ផ្លូវក្រាលកៅស៊ូ (DBST) ប្រវែង ៥.០៨០ ម៉ែត្រ ផ្លូវអ៊ុតកៅស៊ូ (AC) ប្រវែង ៣៣.៤៩៩ ម៉ែត្រ ផ្លូវដីប្រវែង ១៧៧.០០០ ម៉ែត្រ ផ្លូវល្បាយថ្មភ្នំប្រវែង ៤៦.៥០០ ម៉ែត្រ ផ្លូវក្រាលក្រួសក្រហមប្រវែង ១៣៧.៣៩២ ម៉ែត្រ។ សំណង់លូមូលកាត់ផ្លូវចំនួន ៧២ កន្លែង រៀបថ្មម៉ាបចំនួន ៦.៦២០ មែត្រការ៉េ សំណង់លូមូលរំដោះទឹកស្អុយអង្កត់ផ្ចិត០,៨ម៉ែត្រ ប្រវែង ២.៧៥៦ ម៉ែត្រ សំណង់លូអ៊ុយរំដោះទឹកស្អុយប្រវែង ២.៦០០ ម៉ែត្រ។ សាងសង់បង្គោលភ្លើងសូឡាចំនួន ៤០៤ ដើម និងសាងសង់បង្គោលភ្លើង LED ចំនួន ៥៨ ដើម។ សាងសង់ទំនប់បង្ហៀរទឹកចំនួន ២ កន្លែង ដាក់លូមូលចំនួន ១១៨ កន្លែង ជីកស្រះសហគមន៍ចំនួន ០៧ កន្លែង សាងសង់អាងត្រងទឹកភ្លៀងចំនួន ២៩៩ អាង សាងសង់ អណ្ដូងស្នប់ចំនួន ៤២ អណ្ដូង និងផ្ដល់សម្ភារៈ សាងសង់បង្គន់អនាម័យចំនួន ២.៨៩០ បង្គន់។

## សមិទ្ធផល នៃការថែទាំផ្លូវរបស់មន្ទីរសាធារណការ រយៈពេល ៥ឆ្នាំ (២០១៨-២០២២)

| សូចនាករសំខាន់ | ឯកត្តា | ២០១៨ | ២០១៩ | ២០២០ | ២០២១ | ២០២២ |
|---|---|---|---|---|---|---|
| **ការងារថែទាំប្រចាំ** | | | | | | |
| ផ្លូវក្រាលកៅស៊ូ (AC/DBST) | គ.ម | ៩១,២៥០ | ៨១,៥៧០ | ៨៥,៨៨០ | ៨៥,៨៨០ | ១០៧,៣១០ |
| ផ្លូវក្រួសក្រហម | គ.ម | ១០,៧២៨ | ១៣៩,៨៨០ | ១៤៩,៦៤០ | ១៤៦,៣៣០ | ១២៣,០៣០ |
| **ការងារថែទាំខួប** | | | | | | |
| ផ្លូវក្រាលកៅស៊ូ (AC/DBST) | គ.ម | ៤,៥០០ | ៣,៩៤៥ | ៥,៤៤២ | ២,៨៧០ | ២,៩៥០ |
| ផ្លូវបេតុង | គ.ម | | ០ | ០ | ០ | ៤,៧០០ |
| ផ្លូវក្រួសក្រហម | គ.ម | | ៤,៥៦២ | ០ | ០ | ០ |
| លូប្រអប់ | ម៉ែត្រ | ៩ | ៩ | ០ | ១៧២ | ១២ |
| លូអ៊ុយ | ម៉ែត្រ | ១.៧៥០ | ៩៩៥ | ៥.៣៦១ | ៣.៣៨២ | ១.៧៥៨ |
| លូមូលមុខ១០០ | ម៉ែត្រ | ៩៦ | ២០២ | ២៤ | ៨៨ | ៦០ |
| លូមូលមុខ២០០ | ម៉ែត្រ | ១២ | ០ | ១៧៨ | ៤៨ | ៣៦ |
| ប្រឡាយ | ម៉ែត្រ | ០ | ១.៣៦០ | ១៣៦ | ២៧០ | ០ |
| **ការងារជួសជុលបន្ទាន់** | | | | | | |
| ផ្លូវក្រាលកៅស៊ូ (AC/DBST) | គ.ម | ០ | ០ | ០ | ៦ ០៣០ | ១,៣៣៨ |
| ផ្លូវបេតុង | គ.ម | ១៥៤ | ០ | ០ | ០ | ០ |
| ផ្លូវក្រួសក្រហម | គ.ម | ៣,៦២៥ | ៩០០ | ២០,៨៥២ | ៨,៧៥៥ | ៤,៨៦៨ |
| ស្ពានបេឡេត៍ | ម៉ែត្រ | ២១ | ២១ | ០ | ០ | ០ |
| លូអ៊ុយ | ម៉ែត្រ | ១៦០ | ០ | ០ | ០ | ០ |
| លូមូលមុខ១០០ | ម៉ែត្រ | ៧២៤ | ០ | ០ | ០ | ០ |
| លូមូលមុខ២០០ | ម៉ែត្រ | ១ | ០ | ០ | ០ | ០ |
| ប្រឡាយ | ម៉ែត្រ | ១ | ១០០ | ០ | ០ | ៤៩៣ |
| ការងារចុះត្រួតពិនិត្យ ទប់ស្កាត់ និងហាមឃាត់ការសាងសង់សំណង់(ចំណីផ្លូវ) | កន្លែង | ២៣៧ | ៨ | ០ | ០ | ០ |
| ការងារចុះបញ្ជីអាជីវកម្មដឹកជញ្ជូន | គ្រឿង | ១០៨ | ១៤៤ | ១៦៧ | ៧១ | ៩១ |
| ការងារត្រួតពិនិត្យយានយន្តខុសលក្ខណៈបច្ចេកទេស | គ្រឿង | ៧៤៤ | ៣៩៦ | ១៨១ | ០ | ០ |
| ចុះបញ្ជី និងផ្តល់ច្បាប់អាជីវកម្មយានដ្ឋានកែច្នៃ ដំឡើង និងសាខាសាលាបង្រៀន បើកបរយានយន្ត | គ្រឿង | ៧ | ៤៤ | ៤៨ | ៥២ | ២០ |
| ការងារចុះបញ្ជីយានយន្ត | គ្រឿង | ៩១២ | ១.០៧៥ | ៧១៣ | ៩៧ | ២៤ |
| ការងារចុះបញ្ជីផ្តល់បណ្ណបើកបរយានយន្ត | គ្រឿង | ៣.៤២៩ | ៥.១៦៣ | ៤.៥២៩ | ១.៤៧០ | ០ |
| ការងាត្រួតពិនិត្យលក្ខណៈបច្ចេកទេសយានយន្ត | គ្រឿង | ៣២៩ | ១.០១៥ | ១.៦៦៨ | ៧២១ | ១.៦៦៦ |
| ការងារផ្សព្វផ្សាយច្បាប់ ស្តីពីសុវត្ថិភាពចរាចរណ៍ផ្លូវគោក | គ្រឿង | ៥.១៨៤ | ៤.៨២៧ | ៤.៨៣១ | ១.៨៩១ | ៤.០៩៩ |

❖ ***វិស័យទេសចរណ៍៖*** ខេត្តប៉ៃលិន មានរមណីយ៍ដ្ឋានសរុបចំនួន ០៨ កន្លែង ក្នុងនោះមាន រមណីយ៍ដ្ឋានវប្បធម៌ប្រវត្តិសាស្ត្រ (ភ្នំយ៉ាត) ០១ កន្លែង រមណីយ៍ដ្ឋានធម្មជាតិ (អូរទុរេន អូរតាអែម ស្ទឹងកុយ អន្លង់ខៀវ) ០៤ កន្លែង កសិទេសចរណ៍ (ចំការខ្នុរ) ០១កន្លែង អេកូទេសចរណ៍ (ភ្នំខៀវ និងទឹកធ្លាក់ក្បាលដំរី) ០២កន្លែង ដែលមានភាពទាក់ទាញទេសចរណ៍យ៉ាងខ្លាំង ជាពិសេសតំបន់អេកូទេសចរណ៍។ ជាក់ស្តែងរយៈពេល៥ឆ្នាំ ចាប់ពីឆ្នាំ២០១៨ ដល់ឆ្នាំ២០២២នេះ ខេត្តប៉ៃលិន ទទួលបានភ្ញៀវទេសចរ មកទស្សនាកម្សាន្តសរុបចំនួន **៩៧០.៥៤៩ នាក់** ក្នុងនោះមាន ភ្ញៀវទេសចរជាតិចំនួន **៩៦៣.៤២៤ នាក់** និងភ្ញៀវទេសចរអន្តរជាតិចំនួន **៧.១២៥ នាក់** បើប្រៀបធៀបនឹង៥ឆ្នាំមុនមានការកើនឡើងគួរឱ្យកត់សម្គាល់។ នេះក៏ដោយសារការខិតខំប្រឹងប្រែងយកចិត្តទុកដាក់ និងមានការចង្អុលបង្ហាញពីក្រសួងពាក់ព័ន្ធ រដ្ឋបាលខេត្តបានសហការជាមួយមន្ទីរជំនាញធ្វើការរៀបចំនូវរមណីយ៍ដ្ឋាន ទីប្រជុំជន និងទីក្រុងស្អាត សេវាល្អ ដែលធ្វើឱ្យភ្ញៀវទេសចរ ទទួលបាននូវទំនុកចិត្ត ហើយអញ្ជើញមកទស្សនាកំសាន្តក្នុងខេត្តប៉ៃលិន។ កន្លងមកខេត្តប៉ៃលិន ធ្លាប់ទទួលបានចំណាត់ថ្នាក់លេខ៣ "**ផ្ការំដួល១ទង**" ទូទាំងប្រទេស។ ទន្ទឹមនឹងនេះ យើងបានយកចិត្តទុកដាក់លើការអភិវក្សលើកកម្ពស់អេកូទេសចរណ៍ ការកសាងទីក្រុងស្អាត (ទីក្រុងបៃតង) ដើម្បីចូលរួមក្នុងចលនាប្រឡងប្រណាំង "ទីក្រុងស្អាត រមណីយដ្ឋានស្អាត សេវាល្អ បដិសណ្ឋារកិច្ចល្អ" លើកទី៣ នាពេលកន្លងទៅថ្មីៗនេះ។ ក្រៅពីរមណីយ៍ដ្ឋាន ខេត្តប៉ៃលិនមានសណ្ឋាគារចំនួន ១០ កន្លែង ផ្ទះសំណាក់ ២៦ កន្លែង ភោជនីយ៍ដ្ឋាន និងអាហារដ្ឋាន ៧៨ កន្លែង កន្លែងម៉ាស្សា ១៦ កន្លែង រីស៊ តចំនួន ០៣ កន្លែង ផ្ទះរំហែរ ០១ កន្លែង ផ្ទះជួល ១៣១ កន្លែង កីឡាទេសចរណ៍ ១៧ កន្លែង ខារ៉ាអូខេចំនួន ០៦ កន្លែង និងឌីស្កូតែកចំនួន ០១ កន្លែង។

## ៤. ផ្នែកសង្គម

❖ ***វិស័យគាំពារសង្គម៖*** ដោយមានការយកចិត្តទុកដាក់ពីសំណាក់រាជរដ្ឋាភិបាល ជាពិសេស**សម្តេចតេជោនាយករដ្ឋមន្ត្រី** ដែលបានយកចិត្តទុកដាក់ដោះស្រាយជីវភាពរស់នៅរបស់ប្រជាជនតាមកម្មវិធីឧបត្ថម្ភសាច់ប្រាក់ និងសម្ភារៈ ដល់ប្រជាពលរដ្ឋនៅក្នុងព្រឹត្តិការណ៍កូវីដ-១៩។ ជាក់ស្តែងគិតត្រឹមថ្ងៃទី៣១ ខែមករា ឆ្នាំ២០២៣នេះ រដ្ឋបាលខេត្តប៉ៃលិន បានអនុវត្តកម្មវិធីឧបត្ថម្ភសាច់ប្រាក់ដូចខាងក្រោម៖

- ឧបត្ថម្ភសាច់ប្រាក់ជូនស្ត្រី និងកុមារក្រោមអាយុ២ឆ្នាំ សរុបរួមចំនួន ១.៩៨៨ នាក់ ក្នុងនោះស្ត្រីមានផ្ទៃពោះចំនួន ១.៣៨៦ នាក់ ស្ត្រីសំរាលកូនចំនួន ៤១៦ នាក់ កុមារអាយុក្រោម២ឆ្នាំចំនួន ១៨៦ នាក់។ ស្ត្រីមានផ្ទៃពោះមកទទួលសេវាសុខភាពសរុបចំនួន ១៤.៧៨៩ ករណីចំណាយទឹកប្រាក់សរុបចំនួន **៩២៤.៦៣០.០០០** រៀល (ប្រាំបួនរយម្ភៃបួនលាន ប្រាំមួយរយសាមសិបពាន់រៀលគត់) ក្នុងនោះ ស្ត្រីមានផ្ទៃពោះចំនួន ២.២២១ ករណី ស្ត្រីសំរាលកូន ១.៣០០ ករណី កុមារ ១១.២៦៨ ករណី។
- ឧបត្ថម្ភសាច់ប្រាក់ជូនគ្រួសារក្រីក្រ (កម្រិត១ និងកម្រិត២) និងងាយរងគ្រោះក្នុងអំឡុងពេលប្រយុទ្ធនឹងជម្ងឺកូវីដ-១៩ សរុបបានចំនួន ៥.៧៨៥ នាក់ ស្មើនឹងទឹកប្រាក់សរុបចំនួន

២២.៩០៦.១៤៩.០០០ រៀល (ម្ភៃពីរប៊ីលាន ប្រាំបួនរយប្រាំមួយលាន មួយរយសែសិបប្រាំបួនពាន់រៀល)។

- ឧបត្ថម្ភសាច់ប្រាក់ជូនគ្រួសារក្រីក្រកំឡុងពេលបិទខ្ទប់ចំនួន ៣៤ គ្រួសារ ទឹកប្រាក់សរុបចំនួន **១០.០៣៩.៩០០** រៀល (ដប់លាន សាមសិបប្រាំបួនពាន់ ប្រាំបួនរយរៀល)។
- បើកផ្តល់សាច់ប្រាក់ ជូនគ្រួសារងាយរងហានិភ័យក្នុងអំឡុងពេលមានសម្ពាធអតិផរណា សរុបរួមចំនួន ២.៣៧១ គ្រួសារ ស្មើនឹងទឹកប្រាក់ឧបត្ថម្ភសរុបចំនួន ៣៦៧.១៧៤.៣០០ រៀល (បីរយហុកសិបប្រាំពីរលាន មួយរយចិតសិបបួន បីរយរៀល)។ គ្រួសារដែលបើកប្រាក់ពីបញ្ជរវិងចំនួន ២.២៩៦ គ្រួសារ ស្មើនឹងទឹកប្រាក់ដែលអ្នកទទួលផលបានបើកចំនួន **៣៥៦.២៣៤.៨០០** រៀល (បីរយហាសិបប្រាំមួយលាន ពីររយសាមសិបបួនពាន់ ប្រាំបីរយរៀលគត់)។

| ល.រ | សូចនាករ | លទ្ធផលប្រចាំឆ្នាំ | | | | | សរុបរួម |
|---|---|---|---|---|---|---|---|
| | | ២០១៨ | ២០១៩ | ២០២០ | ២០២១ | ២០២២ | |
| 1 | កម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនស្ត្រីមានផ្ទៃពោះ និងកុមារអាយុក្រោម ២ឆ្នាំ | 0 | 814 | 617 | 562 | 61 | **2,054** |
| 2 | កម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនគ្រួសារក្រីក្រ និងងាយរងគ្រោះក្នុងអំឡុងពេលប្រយុទ្ធនឹងជម្ងឺកូវីដ-១៩ | 0 | 5,318 | 237 | 230 | 0 | **5,785** |

❖ **វិស័យសុខាភិបាល ៖** នៅក្នុងខេត្តប៉ៃលិន មានកន្លែងបម្រើសេវាផ្នែកសុខាភិបាលចំនួន ៧៨ កន្លែង ក្នុងនោះមាន មន្ទីរពេទ្យបង្អែកខេត្ត ចំនួន ០១ កន្លែង បន្ទប់ពិគ្រោះព្យាបាលជំងឺ ៣២ បន្ទប់ បន្ទប់ថែទាំនិងព្យាបាលជំងឺ មាត់ធ្មេញ ០៧ បន្ទប់ បន្ទប់ថែទាំជំងឺ ១៨ បន្ទប់ ឱសថស្ថាន ១៤ កន្លែង និងបន្ទប់ថែទាំផ្ទៃពោះ ០៦ កន្លែង មណ្ឌលសុខភាព ០៧ កន្លែង។ ក្នុងរយៈពេល៥ឆ្នាំកន្លងមក ប្រជាពលរដ្ឋបានមកពិនិត្យពិគ្រោះជំងឺទូទៅជូនប្រជាពលរដ្ឋចំនួន ៩៨.១៦២ នាក់ ស្ត្រីមកពិនិត្យផ្ទៃពោះបានចំនួន ១១.៥៤០ នាក់ ស្ត្រីមកសំរាលកូនចំនួន ៤៦.៣១៥ នាក់ ប្រជាពលរដ្ឋមកសំរាកព្យាបាលចំនួន ៣៩.៤៨២ នាក់។

ដោយឡែកការអនុវត្តនូវវិធានការនានារបស់រាជរដ្ឋាភិបាល ក្នុងការបង្កើនប្រសិទ្ធភាព នៃការងារប្រយុទ្ធប្រឆាំងការរីករាលដាលនៃជំងឺកូវីដ-១៩ រដ្ឋបាលខេត្តប៉ៃលិន បានប្រើប្រាស់កម្លាំងសរុប មធ្យោបាយសរុប ប្រកបដោយស្មារតីយកចិត្តទុកដាក់ខ្ពស់។ ជាក់ស្តែងរដ្ឋបាលខេត្ត បានធ្វើសកម្មភាពជួយឧបត្ថម្ភជីវភាពដល់ប្រជាពលរដ្ឋក្នុងមូលដ្ឋាន និងពលករដែលវិលត្រឡប់មកពីប្រទេសថៃ បានជាបន្តបន្ទាប់ និងបានរៀបចំ ឱ្យមានជាមណ្ឌលចត្តាឡីស័ក មណ្ឌលព្យាបាលជំងឺ និងផ្តល់វ៉ាក់សាំងការពារជំងឺកូវីដ-១៩ ជូនប្រជាពលរដ្ឋ។ អ្នកមកធ្វើចត្តាឡីស័កសរុបចំនួន **២៨.៦៦៣ នាក់ ស្រី ១២.៤៥៣ នាក់** អ្នកឆ្លងជំងឺកូវីដ-១៩ សរុបចំនួន ៣.១០៣ នាក់ ស្រី ១.៤៨៣នាក់ ព្យាបាលជំងឺកូវីដ-១៩ ជាសះស្បើយសរុបចំនួន

៣.០៩៥ នាក់ ស្រី ១.៤៨០ នាក់ (អ្នកស្លាប់ដោយសារជំងឺកូវីដ-១៩ សរុបចំនួន ០៨នាក់ ស្រី ០៣នាក់) ។ គិតត្រឹមថ្ងៃទី៣១ ខែមករា ឆ្នាំ២០២៣ វ៉ាក់សាំងដែលចាក់ទូទាំងខេត្តបានចំនួន ២១៨.៧៧២ ដូស ក្នុងនោះមាន ចាក់វ៉ាក់សាំងជូនប្រជាពលរដ្ឋចាប់ពីអាយុ១៨ឆ្នាំឡើង សរុបចំនួន ៤០.៩៩៦ នាក់ កុមារចាប់ពីអាយុ១២ដល់ក្រោម១៨ឆ្នាំ សរុបចំនួន ១០.០០៩ នាក់ កុមារចាប់ពីអាយុ៦ដល់ក្រោម១២ឆ្នាំ សរុប ៩.៥០៩ នាក់ កុមារអាយុ៥ឆ្នាំ ចំនួនសរុប ១.៩២៥ នាក់ កុមារអាយុ៣ឆ្នាំដល់ក្រោម៥ឆ្នាំ ចំនួនសរុប ៣.២០៣ នាក់ និងបានចាក់វ៉ាក់សាំងជូនអតីតយុទ្ធជន និងគ្រួសារអតីតយុទ្ធជន សរុបចំនួន ១.៥១៥ នាក់។

❖ **វិស័យអប់រំ យុវជន និងកីឡា៖** គិតមកត្រឹមរយៈពេល៥ឆ្នាំចុងក្រោយ (២០១៨-២០២២) នៅក្នុងខេត្តប៉ៃលិន មានគ្រឹះស្ថានមធ្យមសិក្សាចំនួន៩សាលា ក្នុងនោះវិទ្យាល័យចំនួន ៣ កន្លែង និងអនុវិទ្យាល័យចំនួន ៦ កន្លែង មានសិស្សសរុប ៥.៤៨៥ នាក់ ស្រី ២.៩៨០ នាក់។ សាលាបឋមសិក្សាចំនួន ៥៣ សាលា សិស្សសរុប ១០.២៣១ នាក់ ស្រី ៥.០២៧ នាក់។ សាលាបឋមសិក្សាឯកជនចំនួន ៩សាលា សិស្សសរុប ១.៤០៤ នាក់ ស្រី ៦៥២ នាក់។ មត្តេយ្យសិក្សាសាធារណៈចំនួន ២៧ សាលា សិស្សសរុប ១.២១៤ នាក់ ស្រី ៦៧២ នាក់។ មត្តេយ្យសិក្សាសហគមន៍ចំនួន ១២ កន្លែង សិស្សសរុប ៣៣៥ នាក់ ស្រី ១៥៧ នាក់។ មត្តេយ្យ សិក្សាឯកជនចំនួន ១១ សាលា មានសិស្សសរុប ៦៤១ នាក់ ស្រី ២៩៣ នាក់ និងមានបុគ្គលិកអប់រំសរុបចំនួន ៨៥៨ នាក់ ស្រី ៤១៨ នាក់។ បើប្រៀបធៀបនឹង៥ឆ្នាំមុន គឺមានការកើនឡើងគួរជាទីមោទនៈ។

**-អំពីការប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ៖** ៥ឆ្នាំចុងក្រោយនេះ ខេត្តប៉ៃលិនមានបេក្ខជនប្រឡងចំនួន **២.៤០៦** នាក់ ស្រី **១.៣០០** នាក់ បេក្ខជនបានប្រឡងជាប់ចំនួន ១.៧៥៩ នាក់ ស្មើនឹង ៧២,២៣% ស្រី ៩៨៧ នាក់ ៧៥,១៩% ធៀបនឹងបេក្ខជនសរុប។ ក្នុងនោះសិស្សទទួលបាននិទ្ទេសA ចំនួន **៨** នាក់ ស្រី ៥ នាក់ និទ្ទេសB ចំនួន **៤១** នាក់ ស្រី ៣១ នាក់ និទ្ទេសC ចំនួន **១២៩** នាក់ ស្រី ៨៨ នាក់ និទ្ទេសDចំនួន **៣២៧** នាក់ ស្រី ២០៤ នាក់ និងនិទ្ទេសE ចំនួន **៧៤៤** នាក់ ស្រី ៣៩៦ នាក់។

**-អំពីកីឡា៖** បានដឹកនាំកីឡាករចូលរួមប្រកួតកីឡាវ៉ូវីណាម ជ្រើសរើសជើងឯកថ្នាក់ជាតិឆ្នាំ២០២០ ទទួលបានមេដាយមាសចំនួន ០១ គ្រឿង ប្រាក់ចំនួន ០១ គ្រឿង និងមេដាយសំរឹទ្ធចំនួន ០១ គ្រឿង។ ចូលរួមការប្រកួតកីឡាសិស្សបឋមសិក្សាថ្នាក់ជាតិ ទទួលបានមេដាយមាសចំនួន ០៨ គ្រឿង មេដាយប្រាក់ចំនួន ០១ គ្រឿង និងមេដាយសំរឹទ្ធិ ០២ គ្រឿង។ ចូលរួមការប្រកួតកីឡាជាតិលើកទី៣ ឆ្នាំ២០២២ ទទួលបានមេដាយមាសចំនួន ០៨ គ្រឿង មេដាយប្រាក់ចំនួន ០៩ គ្រឿង និងមេដាយសំរឹទ្ធិ ០៩ គ្រឿង។ ចូលរួមប្រកួតប៉េតង់ក្នុងព្រឹត្តិការណ៍ប្រចាំឆ្នាំ ទទួលបានជ័យលាភីលេខ២ ចំនួន ០១ នាក់ និងលេខ៣ ចំនួន ០២ នាក់។

## លទ្ធផលនៃការប្រឡងសញ្ញាបត្រទុតិយភូមិរយៈពេល ៥ឆ្នាំ (២០១៨-២០២២)

| សម័យប្រឡង | បេក្ខជនមកប្រឡង | | បេក្ខជនប្រឡងជាប់ | | ភាគរយប្រឡងជាប់ | | និទ្ទេស A | | និទ្ទេស B | | និទ្ទេស C | | និទ្ទេស D | | និទ្ទេស E | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី |
| 20-08-2018 | 384 | 208 | 239 | 136 | 62.24 | 65.38 | 0 | 0 | 3 | 3 | 19 | 13 | 32 | 16 | 185 | 104 |
| 19-08-2019 | 482 | 247 | 284 | 154 | 58.92 | 62.35 | 0 | 0 | 3 | 1 | 8 | 7 | 39 | 22 | 234 | 124 |
| 21-12-2020 | 510 | 263 | 510 | 263 | 100 | 100 | | | | | | | | | | |
| 27-12-2021 | 480 | 265 | 325 | 183 | 67.71 | 69.06 | 6 | 3 | 6 | 2 | 36 | 25 | 120 | 79 | 157 | 74 |
| 05-12-2022 | 550 | 317 | 401 | 251 | 72.91 | 79.18 | 2 | 2 | 29 | 25 | 66 | 43 | 136 | 87 | 168 | 94 |
| **សរុប** | **2,406** | **1,300** | **1,759** | **987** | **72.36** | **75.19** | **8** | **5** | **41** | **31** | **129** | **88** | **327** | **204** | **744** | **396** |

## ៥. រដ្ឋបាលសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ

❖ **សន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ៖** ក្នុងនាមគណៈបញ្ជាការឯកភាពរដ្ឋបាលខេត្ត បានវាយតម្លៃជារួម បញ្ហាសន្តិសុខ សណ្តាប់ធ្នាប់ និងសុវត្ថិភាពសង្គមមានលក្ខណៈល្អប្រសើរជាង៥ឆ្នាំមុន ទោះបីជាបទល្មើសកើន ៦៣ លើក ស្មើ ២១% (៣៦៦/៣០៣ លើក) ធៀបទៅនឹងរយៈពេលដូចគ្នាពីឆ្នាំ ២០១៣-២០១៧។ បទល្មើសឧក្រិដ្ឋថយ ៥១ លើក ស្មើ ៤៦% (៦១/១១២ លើក) រីឯ បទល្មើសមជ្ឈឹមកើន ១១៤ លើក ស្មើ ៦០% (៣០៥/១៩១ លើក)។

❖ **កិច្ចសហប្រតិបត្តិការស្រាវជ្រាវបង្ក្រាបបទល្មើស៖** បានចំនួន ៧២% នៃបទល្មើសដែលកើតមានឡើង ដោយបង្ក្រាបបាន ២៦៤ ករណី ឃាត់ខ្លួនជនល្មើសចំនួន ៣៦៩ នាក់ (ឧក្រិដ្ឋ ៥៥ ករណី ឃាត់ខ្លួន ៧៥ នាក់ និងមជ្ឈឹម ២០៩ ករណី ឃាត់ខ្លួន ២៩៤ នាក់)។

❖ **ការបង្ក្រាបគ្រឿងញៀន៖** ធ្វើការ ស្រាវជ្រាវ ស៊ើបអង្កេត និងបង្ក្រាបបាន ៣៦១ ករណី ឃាត់ខ្លួន ៩៦០ នាក់ ដកហូតវត្ថុតាងសារធាតុញៀនគ្រប់ប្រភេទសរុប ៧៧៧ កញ្ចប់ និង ២.០៣៤ គ្រាប់ រថយន្ត ០៧ គ្រឿង ម៉ូតូ ១២២ គ្រឿង អាវុធ ០៣ ដើម កាំភ្លើងខ្យល់កែច្នៃ ១៧ ដើម រួមទាំងឧបករណ៍សម្ភារកែច្នៃវេចខ្ចប់មួយចំនួនធំ និងបានបញ្ជូនទៅតុលាការចាត់ការបន្ត។

❖ **ការបង្ក្រាបបទល្មើសជួញដូរមនុស្ស៖** បានបង្ក្រាបបទល្មើសជួញដូរមនុស្សចំនួន ០៩ ករណី ឃាត់ខ្លួនជនសង្ស័យ ១៦ នាក់ (ស្រី ០៨ នាក់) ជនបរទេស ០២ នាក់ (ថៃ ០១ នាក់ វៀតណាម ០១ នាក់) រំដោះជនរងគ្រោះបាន ២៩ នាក់ រួមមាន៖ អំពីជួញដូរមនុស្ស ០៣ ករណី ឃាត់ខ្លួន ០៣ នាក់ (ស្រី ០១ នាក់) រំដោះជនរងគ្រោះ ០២ នាក់ និងអាជីវកម្មផ្លូវភេទ ០៦ ករណី ឃាត់ខ្លួន ១៣ នាក់ (ស្រី ០៧ នាក់) ជនបរទេស ០២ នាក់ (ថៃ ០១ នាក់ វៀតណាម ០១ នាក់) រំដោះជនរងគ្រោះ ២៧ នាក់ (បញ្ជូនទៅមន្ទីរសង្គមកិច្ច ០៧ នាក់ អង្គការ ១៣ នាក់ និងបញ្ជូនអាណាព្យាបាលវិញ ០៩ នាក់។

❖ **ការបង្ក្រាបក្មេងទំនើង៖** បានបង្ក្រាបករណីក្មេងទំនើងចំនួន ១២១ ករណី ឃាត់ខ្លួន ៣២៥ នាក់ (ស្រី ១០ នាក់)។ ក្នុងនោះបានកសាងសំណុំរឿងបញ្ជូនទៅសាលាដំបូងខេត្ត ចំនួន ៣៩ ករណី មនុស្ស ១២១ នាក់ (ស្រី ០១ នាក់) និងអនុវត្តវិធានការរដ្ឋបាល ៨២ ករណី មនុស្ស ២០៤ នាក់ (ស្រី ០៩ នាក់) ដោយបានធ្វើកិច្ចសន្យាអប់រំណែនាំឱ្យបញ្ឈប់សកម្មភាព និងតម្លើងបញ្ជីមុខសញ្ញា។

❖ **ការបង្ក្រាបបទល្មើសល្បែងស៊ីសង៖** បានបង្ក្រាបចំនួន ៣២ ករណី ឃាត់ខ្លួន ១៤៣ នាក់ (ស្រី ៨១ នាក់) ដកហូតកាំភ្លើង ០១ ដើម រថយន្ត ០៥ គ្រឿង គោយន្តកន្ត្រៃយ៍ ០១ គ្រឿង ម៉ូតូ ៥៨ គ្រឿង កុំព្យូទ័រ ៣៤ គ្រឿង Monitor ១៧ គ្រឿង Wireless ០៧ គ្រឿង CPU ០៩ គ្រឿង ម៉ាស៊ីនព្រីន ០១ គ្រឿង ដុំទប់ភ្លើង ០៨ គ្រឿង និង ឧបករណ៍ សម្ភារមួយចំនួន។ ក្នុងនោះ បានកសាងសំណុំរឿងបញ្ជូនទៅតុលាការ ០៧ ករណី មនុស្ស ២៥ នាក់ (ស្រី ១២ នាក់) និង អនុវត្តវិធានការរដ្ឋបាល ២៥ ករណី មនុស្ស ១១៨ នាក់ (ស្រី ៦៩ នាក់) ដោយធ្វើកិច្ចសន្យាអប់រំបញ្ឈប់សកម្មភាព។

## ៦. លទ្ធផលបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ឆ្នាំ២០២២

ជារួមការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៥នេះ មានបរិយាកាសល្អដោយគ្រប់ភាគីពាក់ព័ន្ធបានចូលរួមប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់តាមភារកិច្ចរៀងៗខ្លួន ធ្វើឱ្យការបោះ

ឆ្នោតបានប្រព្រឹត្តទៅដោយសេរី ត្រឹមត្រូវ យុត្តិធម៌ គ្មានអំពើហិង្សា គ្មានការគំរាមកំហែងចំពោះបេក្ខជន ឬគណបក្សនយោបាយណាមួយឡើយ។ ដំណើរការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ឆ្នាំ២០២២ នៅគ្រប់ការិយាល័យបោះឆ្នោត ទាំង១១៨ ការិយាល័យក្នុងខេត្ត មានប្រជាពលរដ្ឋច្រើនកុះករបានទៅបោះឆ្នោត និងដំណើរការបោះឆ្នោតបានអនុវត្តតាមនីតិវិធីហើយសភាពការណ៍នយោបាយ សន្តិសុខ សុវត្ថិភាព និងសណ្តាប់ធ្នាប់ល្អប្រសើ។ ប្រជាពលរដ្ឋមានឈ្មោះក្នុងបញ្ជីបោះឆ្នោតចំនួន ៤២.២៦២ នាក់ ប្រជាពលរដ្ឋទៅបោះឆ្នោតចំនួន ៣១.៥៩៨ នាក់ ស្មើនឹង ៧៤,៧៤% នៃអ្នកមានឈ្មោះក្នុងបញ្ជីបោះឆ្នោត។ គណបក្សប្រជាជនកម្ពុជាទទួលបាន ២៥.៤៥៦សំឡេង គណបក្សភ្លើងទៀនទទួលបានចំនួន ៥.០៩៥ សំឡេង គណបក្សខ្មែររួបរួមទទួលបានចំនួន ៥៤៤ សំឡេង គណបក្សប្រជាធិបតេយ្យមូលដ្ឋាន ចំនួន ២០ សំឡេង និងគណបក្សសញ្ញាតិខ្មែរទទួលបាន ៧ សំឡេង។

**៧. ទិសដៅការងារអនុវត្តបន្ត**

រដ្ឋបាលខេត្តប៉ៃលិន បន្តយកចិត្តទុកដាក់ខ្ពស់ ក្នុងការអភិវឌ្ឍខេត្ត ឱ្យមានការរីចម្រើនលើគ្រប់វិស័យ ទាំងផ្នែកសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ ផ្នែកសេដ្ឋកិច្ច ផ្នែកសង្គមកិច្ច ផ្នែកបរិស្ថាន និងសមិទ្ធផលហេដ្ឋារចនាសម្ព័ន្ធរូបវន្តដាច្រើន ជាពិសេសការលើកកម្ពស់កម្រិតជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ ដោយរដ្ឋបាលខេត្តបានខិតខំស្រាវជ្រាវ ស្វែងរកផលិតផលដែលជាសក្តានុពលរបស់ខេត្ត ដើម្បីជំរុញនូវចលនា "ភូមិ១ផលិតផល១" សំដៅបង្កើតការងារនៅមូលដ្ឋានផ្ទាល់ កាត់បន្ថយការធ្វើចំណាកស្រុក អភិវឌ្ឍន៍នូវចំណេះដឹង និងបច្ចេកទេសដល់ប្រជាពលរដ្ឋ លើកស្ទួយផលិតផលខ្មែរ ទាំងបរិមាណ និងគុណភាព ឆ្លើយតបទៅនឹងតម្រូវការទីផ្សារ ព្រមទាំងអាចទាក់ទាញភ្ញៀវទេសចរផងដែរ។

១. បន្តអនុវត្តយ៉ាងម៉ឺងម៉ាត់ និងត្រឹមត្រូវតាមរដ្ឋធម្មនុញ្ញ ច្បាប់ គោលនយោបាយ បទបញ្ជា លិខិតបទដ្ឋានគតិយុត្តរបស់រាជរដ្ឋាភិបាល ក្រសួងមហាផ្ទៃ និងក្រសួងស្ថាប័ននានា។ ពង្រឹងប្រសិទ្ធិភាពការគ្រប់គ្រងរដ្ឋបាលដែនដី អនុវត្តច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានីខេត្ត ក្រុង ស្រុក ខណ្ឌ ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំសង្កាត់ គោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការ និងចូលរួមអនុវត្តកម្មវិធីកំណែទម្រង់ស៊ីជម្រៅរបស់ រាជរដ្ឋាភិបាល។

**២.** លើកម្ពស់ការរក្សាសន្តិសុខនយោបាយ សន្តិសុខសណ្តាប់ធ្នាប់សាធារណៈ ការអនុវត្តគោលនយោបាយ "ភូមិ ឃុំ សង្កាត់មានសុវត្ថិភាព" ឱ្យកាន់តែល្អប្រសើរថែមទៀត ដើម្បីភាពសុខដុមរមនារបស់ប្រជាពលរដ្ឋ។ បន្តលើកកម្ពស់ការរក្សាសន្តិសុខ នយោបាយ និងសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ សម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ ឆ្នាំ២០២៣ និងអនុវត្តសកម្មភាពការងារតាមប្រតិទិន នៃការបោះឆ្នោតរបស់ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត។

៣. ជំរុញការអនុវត្តផែនការអភិវឌ្ឍខេត្តរយៈពេលប្រាំឆ្នាំ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលរបស់ក្រុមប្រឹក្សាខេត្ត ការអនុវត្តផែនការតាមវិស័យ និងជំរុញការអភិវឌ្ឍន៍គម្រោងហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ ធារាសាស្ត្រ អប់រំ សុខាភិបាល ដើម្បីជំរុញការអភិវឌ្ឍជីវភាពរស់នៅឱ្យប្រសើរឡើង ថែរក្សាសុខុមាលភាព និងការកាត់បន្ថយ ភាពក្រីក្ររបស់ប្រជាជន ។

៤. បន្តរៀបចំផែនការ និងជំរុញល្បឿននៃការអភិវឌ្ឍតាមវិស័យ ដើម្បីលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាជនដូចខាងក្រោម៖

- **ការអភិវឌ្ឍវិស័យកសិកម្ម** ៖ លើកកម្ពស់ការផ្តល់បច្ចេកទេសផលិតកម្មកសិកម្ម ដល់កសិករ ដើម្បី អភិវឌ្ឍបង្កើនផលិតភាព តាមរយៈការអនុវត្តគោលនយោបាយអភិវឌ្ឍន៍វិស័យកសិកម្ម របស់រាជរដ្ឋាភិបាល ជំរុញការចិញ្ចឹមសត្វ វារីវប្បកម្ម ការដាំដុះដំណាំកសិ-ឧស្សាហកម្ម និងបន្តអភិវឌ្ឍន៍ សហគមន៍កសិកម្ម ដើម្បីផលិតផលកសិកម្មដែលជាតម្រូវការទីផ្សារ និងជួសជុលស្តារ ប្រព័ន្ធប្រឡាយ សំណង់ធារាសាស្ត្រ ដើម្បីស្រោចស្រពផ្ទៃដីដាំដុះ។
- **ការអភិវឌ្ឍវិស័យឧស្សាហកម្ម សិប្បកម្ម** ៖ ជំរុញការអនុវត្តគោលនយោបាយរបស់រាជរដ្ឋាភិ-បាលផ្តល់ឱកាសជំរុញឱ្យបរិស្ថានវិនិយោគល្អប្រសើ ជាមួយវិស័យឯកជនដើម្បីមកវិនិយោគនៅ ខេត្តប៉ៃលិន ដើម្បីឱ្យប្រជាពលរដ្ឋមានការងារធ្វើ ទទួលបានប្រាក់ចំណូល មធ្យមកម្រិតខ្ពស់នៅឆ្នាំ២០២៣ និងលើកកម្ពស់ ជីវភាពរស់នៅឱ្យកាន់តែប្រសើរ។
- **ពង្រឹងការគ្រប់គ្រងដីធ្លី** ៖ រៀបចំប្លង់គោល ផែនការប្រើប្រាស់ដីធ្លី ការស្នើសុំកាត់ឆ្វៀលដីសម្រាប់ជាកម្មសិទ្ធិជូនប្រជាពលរដ្ឋពីដីតំបន់ការពារ និងប្រើប្រាស់ច្រើនយ៉ាងសំឡូត ភូមិសាស្ត្រប៉ៃលិន និងការអភិវឌ្ឍវិស័យសំណង់ហេដ្ឋារចនាសម្ព័ន្ធគ្រប់ ប្រភេទតាមលិខិតបទដ្ឋានជាធរមាន។
- **ការអភិវឌ្ឍវិស័យសេវាកម្ម** និងវិស័យសាធារណៈ ៖ ពង្រឹង និងពង្រីកការផ្តល់សេវារដ្ឋបាលនៅថ្នាក់ខេត្ត ក្រុង ស្រុក ឃុំ សង្កាត់ តាមរយៈយន្តការច្រកចេញចូលតែមួយ។ អភិវឌ្ឍទីផ្សារសម្រាប់ប្រជាពលរដ្ឋឱ្យកាន់តែល្អប្រសើរមានគុណភាព និងតម្លៃសមរម្យ។ អភិវឌ្ឍផ្សារឱ្យមានបរិស្ថានល្អ សម្រាប់ប្រជាជនធ្វើអាជីវកម្ម បង្កើន ការគ្រប់គ្រងការលក់ដុំ លក់រាយទំនិញគ្រប់ប្រភេទ ឱ្យមានគុណភាព និងតម្លៃសមរម្យ
- **អភិវឌ្ឍគោលដៅទេសចរណ៍សំខាន់ៗ៖** រៀបចំអភិវឌ្ឍន៍តំបន់ទេសចរណ៍ធម្មជាតិ តំបន់ទេសចរណ៍ វប្បធម៌ប្រវត្តិសាស្ត្រ និងអភិវឌ្ឍន៍សេវាទេសចរណ៍ សណ្ឋាគារ ផ្ទះសំណាក់ សេវាកំសាន្តភោជនីយដ្ឋាន..) ឱ្យបានល្អប្រសើ បង្កើនផលិតផលទេសចរណ៍ ជំរុញចលនាប្រឡងប្រណាំងទីក្រុងស្អាត រមណីយដ្ឋានស្អាត ទីក្រុងបៃតង។
- **ការអភិវឌ្ឍវិស័យសង្គមកិច្ច** ៖ បន្តជំរុញការអភិវឌ្ឍន៍វិស័យអប់រំ សុខាភិបាល សង្គមកិច្ច ដើម្បីឱ្យ ប្រជាជនមានចំណេះដឹង សុខុមាលភាពល្អប្រសើ សម្រាប់ជាធនធានមនុស្សដ៏មានសក្តានុពលក្នុងការចូលរួមអភិវឌ្ឍន៍សេដ្ឋកិច្ច សង្គម និងអនុវត្តគោលនយោបាយគាំពារសង្គមនានារបស់ រាជរដ្ឋាភិបាលក្នុងការជួយគាំទ្រឱ្យប្រជាជនរស់នៅមានជីវភាពល្អប្រសើ។

ក្រោមការដឹកនាំរបស់រាជរដ្ឋាភិបាល ក្រសួងមហាផ្ទៃ និងស្ថាប័នថ្នាក់ជាតិ រដ្ឋបាលខេត្តប៉ៃលិនសម្រេចបាននូវសមិទ្ធផលធំៗ ស្របតាមកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាលដោយបានអនុវត្តត្រឹមត្រូវតាមគោលការណ៍នីតិរដ្ឋ និងអនុវត្តការងារស្របតាមបែបបទលិខិតបទដ្ឋានគតិយុត្តនិងគោលការណ៍ច្បាប់។ មន្ត្រីរាជការ កងកម្លាំងប្រដាប់អាវុធ អាជ្ញាធរគ្រប់លំដាប់ថ្នាក់ និងប្រជាពលរដ្ឋគ្រប់មជ្ឈដ្ឋាន បានចូលរួមយ៉ាងសកម្មក្នុងការថែរក្សា ពង្រឹងសន្តិភាព សន្តិសុខសណ្តាប់ធ្នាប់សង្គម

នៅមូលដ្ឋាន និងការលើកកម្ពស់ជីវភាពរស់នៅរបស់ខ្លួន។ ជំរុញការអភិវឌ្ឍជីវភាពរស់នៅរបស់ប្រជាពលរដ្ឋនៅទូទាំងខេត្ត លើកស្ទួយសុខមាលភាព កាត់បន្ថយភាពក្រីក្រ ក៏ដូចជាទិសដៅភារកិច្ចដាក់ចេញដោយក្រសួងមន្ទីរ និងស្ថាប័នពាក់ព័ន្ធ ដោយឈរលើស្មារតីទទួលខុសត្រូវ និងឆន្ទៈមោះមុត មានការប្តេជ្ញាចិត្តខ្ពស់ និងមានសាមគ្គីឯកភាព ផ្ទៃក្នុងដើម្បីសម្រេចជោគជ័យថ្មីៗ ថែមទៀត ស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល។

ជាថ្មីម្តងទៀត ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ ចំពោះ**ឯកឧត្តម ផៃ ស៊ីផាន** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី និងជាប្រធានអង្គភាពអ្នកនាំពាក្យរាជរដ្ឋាភិបាលដែលបានផ្តល់ឱកាសឱ្យរដ្ឋបាលខេត្តប៉ៃលិន ធ្វើសន្និសីទសារព័ត៌មាន ស្តីពី "ភាពជោគជ័យក្នុងរយៈពេល៥ឆ្នាំកន្លងមករបស់រដ្ឋបាលខេត្តប៉ៃលិន" នាពេលនេះ ដើម្បីបង្ហាញសមិទ្ធផលនានាដែលខេត្តប៉ៃលិនសម្រេចបានកន្លងមក និងការអភិវឌ្ឍខេត្តជូនសម្តេច ទ្រង់ ឯកឧត្តម លោកជំទាវ លោក លោកស្រី និងទូរទស្សនិកជន។

ក្នុងឱកាសដ៏ឧត្តុង្គឧត្តមថ្លៃថ្លានេះ នាងខ្ញុំក្នុងនាមក្រុមប្រឹក្សា គណៈអភិបាលខេត្ត ព្រះសង្ឃ មន្ត្រីរាជការកងកម្លាំងប្រដាប់អាវុធ និងប្រជាពលរដ្ឋទូទាំងខេត្តប៉ៃលិន សូមសំដែងនូវសេចក្តីគោរពដឹងគុណ ដ៏ស្មោះអស់ពីដួងចិត្ត ចំពោះគំរូវីរភាពដ៏ឆ្នើមរបស់សម្តេចតេជោ ដែលបានដឹកនាំនាវាកម្ពុជាឆ្ពោះទៅរកសន្តិភាពបង្រួបបង្រួមជាតិ កសាងនិងអភិវឌ្ឍន៍ប្រទេសជាតិ ឱ្យមានការរីកចម្រើនលើគ្រប់វិស័យ។

យើងខ្ញុំទាំងអស់គ្នា សូមប្រកាសគាំទ្រជាឱឡារិក និងពេញទំហឹង គាំទ្រ**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ជា បេក្ខភាពនាយករដ្ឋមន្ត្រី និងជ្រើសតាំង **ឯកឧត្តម ហ៊ុន ម៉ាណែត** ជាបេក្ខភាពនាយករដ្ឋមន្ត្រី សម្រាប់ពេលអនាគត។ សូមអរគុណសន្តិភាព !

សូមគោរពជូនពរ **សម្តេច ទ្រង់ ឯកឧត្តម លោកជំទាវ លោក លោកស្រី** និងទូរទស្សនិជន សូមបានប្រកបពុទ្ធពរទាំងបួនប្រការគឺ **អាយុ វណ្ណៈ សុខៈ ពលៈ** កុំបីឃ្លៀងឃ្លាតឡើយ៕

**សូមគោរពអរគុណ !**